# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Mar-2011, 15:30
CMS/CFO: Uch Arun

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ

---

**ដាក់ដោយ៖**

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ផ្ញើជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម **គង់ ស្រីម**, ប្រធាន

ចៅក្រម Motoo NOGUCHI

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម A.KLONOWIECKA-MILART

ចៅក្រម **ស៊ិន រិទ្ធ**

ចៅក្រម C. N. JAYASINGHE

ចៅក្រម **យ៉ា ណារិន**

**ចម្លងជូន៖**

| **មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** | **ជនជាប់ចោទ** | **មេធាវីជនជាប់ចោទ** |
|---|---|---|
| ពេជ អង្គ | នួន ជា | សុន អរុណ |
| Elisabeth SIMONNEAU FORT | អៀង សារី | Michiel PESTMAN<br>Victor KOPPE |
| | អៀង ធីរិទ្ធ | អាង ឧត្តម<br>Michael G. KARNAVAS |
| | ខៀវ សំផន | ផាត់ ពៅស៊ាង<br>Diana ELLIS<br>ស ស្វូវាន<br>Jacques VERGÈS<br>Philippe GRECIANO |

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ("សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង")[១]។ នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១១ ជនជាប់ចោទ នួន ជា ("ជនជាប់ចោទ") បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ("បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី")[២]។ នៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ជនជាប់ចោទតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំអង្គច្បាប់ដោយ (១) អនុវត្តការបកស្រាយមិនត្រឹមត្រូវនៃវិធាន ៦៨[៣] និង (២) ខកខានមិនបានទទួលស្គាល់ថា ដំណោះស្រាយសមស្របតែមួយគត់នៅក្នុងស្ថានភាពនេះ គឺការដោះលែងជាបន្ទាន់[៤]។ ជនជាប់ចោទស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលទុកជាមោឃៈ ឬធ្វើការកែប្រែសេចក្តីសម្រេច និងបង្គាប់ឱ្យមានការដោះលែងជនជាប់ចោទជាបន្ទាន់[៥]។

២. សហព្រះរាជអាជ្ញា អះអាងថាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីត្រូវតែបដិសេធចោលទាំងស្រុងតែម្តង ពីព្រោះ (១) សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងអំពីដំណោះស្រាយនានា មានភាពសមស្រប និងស្ថិតនៅក្នុងវិសាលភាពនៃឆន្ទានុសិទ្ធរបស់អង្គជំនុំជម្រះសាលាដំបូង (២) អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវនូវអំណាចឯករាជ្យរបស់ខ្លួន ក្នុងការបន្តការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្ន និង (៣) ជនជាប់ចោទខកខានមិនបានពន្យល់ថាតើផលប្រយោជន៍

---

[១] អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើសំណើសុំ ដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង")។

[២] បណ្តឹងសាទុក្ខសេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជតក, មេធាវីការពារក្តី, ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១១, ឯកសារ E50/1/1/1 ("បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី")។

[៣] បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី កថាខណ្ឌ ១៣ ដល់ ២០។ ជនជាប់ចោទលើកឡើងថា អជសដ ខកខានមិនបានលើកឡើងឱ្យបានច្បាស់អំពីគោលការណ៍ដំណោះស្រាយស្ពាពរ និងថា អជសដ បកស្រាយដោយភ័ន្តច្រឡំលើវិធាន ៦៨។

[៤] ដូចខាងលើ កថាខណ្ឌ ៣០ ដល់ ៣៥។

[៥] ដូចខាងលើ កថាខណ្ឌ ៣៧។

របស់ខ្លួនបានរងផលប៉ះពាល់បែបណាខ្លះ ដោយសារតែកំហុសនានាដែលខ្លួនបានអះអាងថាមាននៅក្នុងសេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលបានកំណត់លក្ខខណ្ឌអនុលោមតាមបទដ្ឋាន សម្រាប់ការធ្វើបណ្តឹងសាទុក្ខបន្ទាន់តាមវិធាន ១០៤។

## II. បទដ្ឋានសម្រាប់ការពិនិត្យឡើងវិញ

៣. វិធាន ១០៤ ចែងអំពីបទដ្ឋានសម្រាប់ការពិនិត្យឡើងវិញ ដែលចែងថាបណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកទៅលើ "ការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ" [៦]។ ទាក់ទិននឹងចំណុចទីមួយនៃបទដ្ឋាន សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះតុលាការកំពូល គួរស្វែងរកសេចក្តីណែនាំនៅក្នុងការបកស្រាយរបស់តុលាការ ICTY អំពីអ្វីដែលជាលក្ខខណ្ឌតម្រូវក្នុងការបង្ហាញពីការបំពានទៅលើឆន្ទានុសិទ្ធិ[7] ។

## III. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងលើដំណោះស្រាយនានា មានភាពសមស្រប និងស្ថិតនៅក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់ខ្លួន

៤. ជនជាប់ចោទតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំអង្គច្បាប់ដោយមិនទទួលស្គាល់ថា "ដំណោះស្រាយ *តែមួយគត់* ដែលអាចយកមកអនុវត្តបានក្នុងស្ថានភាពបច្ចុប្បន្ន គឺជាការដោះលែងជាបន្ទាន់" អនុលោមតាមលក្ខខណ្ឌនៃវិធាន ៦៨[៨]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានដើរ

---

[៦] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៧) វិសោធនកម្មថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ("វិធាន") វិធាន ១០៤។

[7] *សូមអាន* ជាឧទាហរណ៍ Milošević ទល់នឹង រដ្ឋអាជ្ញា, សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្គំលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការចាត់តាំងមេធាវីការពារក្តី, សំណុំរឿងលេខ: IT-02-54-AR73.7, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ១ វិច្ឆិកា ២០០៤, កថាខ័ណ្ឌទី៩-១០ (ដោយបានថ្លែងថា ការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវបានបដិសេធ ប្រសិនបើសេចក្តីសម្រេចដែលបានតវ៉ានោះ (១) មានមូលដ្ឋានទៅលើការបកស្រាយមិនត្រូវទៅលើច្បាប់ជាធរមាន, (២) មានមូលដ្ឋានលើសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតទៅលើអង្គហេតុ, ឬ (៣) មិនមានភាពត្រឹមត្រូវ ឬ មិនមានភាពសមហេតុផលខ្លាំង ដែលបង្កើតបានជាការរំលោភលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ។

[៨] បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី កថាខណ្ឌ ៣០។

តួនាទី នៅក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការយល់ឃើញថា (១) សាលដីការបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អ.ប.ជ") រួមទាំងផ្នែកស្តីពីការឃុំខ្លួន មិនត្រូវបានទុកជាមោឃៈ ដោយសារកង្វះមូលហេតុភ្លាមៗនោះទេ និង (២) អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការពិចារណាអំពីដំណោះស្រាយសមស្របនៅពេលបញ្ចប់សវនាការ ក្រោយពេលស្តាប់ការសន្និដ្ឋានរបស់ភាគីនានារួច[៩]។

៥. ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងដំណោះស្រាយនានា រួមទាំងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការដោះលែងជាបន្ទាន់មិនមែនជាដំណោះស្រាយសមស្របនោះទេ នេះគឺជាការសមហេតុផល និងជាការលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងវិសាលភាពនៃឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងការអះអាងអំពីសុពលភាពនៃសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អ.ប.ជ សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវ បានគាំទ្រយ៉ាងរឹងមាំដោយច្បាប់យុត្តិសាស្ត្រដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចនោះ ក៏ដូចជានៅក្នុងច្បាប់យុត្តិសាស្ត្រ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា នៅពេលសវនាការស្តីពីការឃុំខ្លួនផងដែរ រួមទាំងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Popović* ផងដែរ[១០]។ នៅក្នុងរឿងក្តី *Popović* អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំដោយមិនបានផ្តល់ហេតុផលគ្រប់គ្រាន់នៅក្នុងការសម្រេចថាជនជាប់ចោទត្រូវបន្តការឃុំខ្លួនទៀត ប៉ុន្តែបានលើកឡើងថា កំហុសប៉ុណ្ណោះមិនគ្រប់គ្រាន់ដើម្បីច្រានចោលសេចក្តីសម្រេចស្តីពីការឃុំខ្លួន របស់អង្គជំនុំជម្រះសាលាដំបូងនោះទេ[១១]។ ស្រដៀងគ្នានេះដែរ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពន្យារពេលធ្វើការពិចារណាបន្ថែមលើដំណោះស្រាយនានា រហូតដល់ដំណាក់កាលចុងក្រោយនៃការជំនុំជម្រះ

---

[៩] *សូមមើល* សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៥ ដល់ ៣៦។

[១០] *សូមមើល* សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៣ ដល់ ៣៥។ ប្រតិចារឹកអំពីសវនាការស្តីពីការឃុំខ្លួន, E1/1.1, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, ៣១ មករា ២០១១, ("ប្រតិចារឹកអំពីសវនាការស្តីពីការឃុំខ្លួន") ប្រតិចារឹក ៥២ ដល់ ៥៣។

[១១] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Popović សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្អំនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានបដិសេធដោះលែងបណ្តោះអាសន្ន Ljubomir Borovčanin, IT-05-88-AR65.3, អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ ICTY, ចុះថ្ងៃទី ១ ខែមីនា ឆ្នាំ ២០០៧ ("*Popović*") កថាខណ្ឌ ១៣, ២០។

ក្តី ក៏មានភាពស៊ីសង្វាក់គ្នាជាមួយនឹងយុត្តិសាស្ត្រអន្តរជាតិ នៅពេលដែលភាពត្រឹមត្រូវនៃដំណោះស្រាយសម្រាប់កំហុសនីតិវិធី ត្រូវបានលើកឡើងនៅពេលបញ្ចប់សវនាការ[១២]។

## IV. អង្គជំនុំជម្រះសាលាដំបូងមិនមានការភ័ន្តច្រឡំនៅក្នុងការអនុវត្តអំណាចឯករាជ្យរបស់ខ្លួនដើម្បីបន្តឃុំខ្លួនជនជាប់ចោទនោះទេ

៦. ជនជាប់ចោទតវ៉ាថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការរក្សាគាត់ នៅក្នុងមន្ទីរឃុំឃាំង សំអាងលើការបកស្រាយច្បាប់ដោយពុំត្រឹមត្រូវតាមវិធាន ៦៨ និងវិធាន ៧៧(១៥) ហើយសេចក្តីសម្រេចនេះក៏ពុំអាចផ្តល់មូលដ្ឋានគតិយុត្តិឲ្យបានគ្រប់គ្រាន់សម្រាប់បន្តឃុំខ្លួន នួន ជា នោះដែរ[១៣]។ ទោះបីជាយ៉ាងណាក៏ដោយ ការទាមទារនេះគ្មានហេតុផលនោះទេ ពីព្រោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការបន្តឃុំខ្លួន នួន ជា ត្រូវបានសំអាងលើវិធាន ៨២ - មិនមែនវិធាន ៦៨ ឬវិធាន ៧៧(១៥) នោះទេ[១៤]។

៧. វិធាន ៨២ បានចែងយ៉ាងច្បាស់អំពីមូលដ្ឋានផ្លូវច្បាប់សម្រាប់បន្តការឃុំខ្លួនជនជាប់ចោទ។ អនុវិធាន ៨២(១) ចែងថា "ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តី លើកលែងករណីដែលមានចែងក្នុងអនុវិធាន ២

---

[១២] *សូមមើល* ឧទាហរណ៍ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Barayagwiza* សាលក្រម និងការផ្តន្ទាទោស ICTR-99-52-T ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ១១០៦ ដល់ ១១០៧ (ដែលបានបន្ធូរបន្ថយទោសរបស់ជនជាប់ចោទ នៅពេលដែលជនជាប់ចោទស្ថិតនៅ ក្នុងការឃុំឃាំងដោយគ្មានការជូនដំណឹងអំពីការចោទប្រកាន់លើគាត់សម្រាប់រយៈពេលមួយនោះទេ)។ រឿងក្តី *Kajelijeli តទល់នឹង រដ្ឋអាជ្ញា* សាលដីកា ICTR-98-44A-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ ICTR ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៥, កថាខណ្ឌ ៣២៣ ដល់ ៣២៤ (ដែលបានបន្ធូរបន្ថយទោសរបស់ជនជាប់ចោទដើម្បីធ្វើការពិចារណាសម្រាប់រយៈពេលមួយ ដែលនៅក្នុងពេលនោះ ជនជាប់ចោទស្ថិតនៅក្នុងការឃុំឃាំងដោយគ្មានការជូនដំណឹងអំពីការចោទប្រកាន់លើគាត់ និងមិនត្រូវបាននាំមកចំពោះមុខចៅក្រមដោយមិនបង្អង់យូរ)។ រឿងក្តី Semanza តទល់នឹង រដ្ឋអាជ្ញា, តុលាការសាលាឧទ្ធរណ៍ ICTR, ២០ ឧសភា ២០០៥, កថាខណ្ឌ ៣២៣-៣២៨ (ដែលបានបន្ធូរបន្ថយទោសរបស់ជនជាប់ចោទដើម្បីធ្វើការពិចារណាសម្រាប់រយៈពេលមួយ ដែលនៅក្នុងពេលនោះ ជនជាប់ចោទស្ថិតនៅក្នុងការឃុំឃាំងដោយគ្មានការជូនដំណឹងអំពីការចោទប្រកាន់លើគាត់)។

[១៣] បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី កថាខណ្ឌ ៣៦។

[១៤] *សូមមើល* សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង ទំព័រ ១៣ ដល់ ១៥។ វិធាន ៨២ នៃវិធានផ្ទៃក្នុង។

ខាងក្រោម"។ អនុវិធាន ៨២(២) ចែងថា "គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាច... បង្គាប់ឲ្យឃុំខ្លួន ជនជាប់ចោទបានស្របតាម[វិធានផ្ទៃក្នុងនេះ]"[១៥]។ ពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុង គាំទ្រអំណះអំណាងដែលថាអត្ថិភាពពីមុននៃកំហុសនីតិវិធី នៅក្នុងសេចក្តីសម្រេចឃុំខ្លួនរបស់អង្គបុរេជំនុំជម្រះ បដិសេធទៅនឹងការបន្តឃុំខ្លួនជនជាប់ចោទ ឬអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបង្គាប់ឲ្យមានការឃុំខ្លួន ដោយអនុលោមតាមអំណាចឯករាជ្យរបស់ខ្លួននោះទេ។ ជនជាប់ចោទមិនបានដកស្រង់យុត្តិសាស្ត្រណាមួយដែលគាំទ្រដល់ការសន្និដ្ឋានបែបនេះទេ។

៨. ដោយសារអង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងត្រឹមត្រូវថា ផ្នែកនៃការឃុំខ្លួនដែលមាននៅក្នុងសេចក្តីសម្រេចរបស់ អបជ លើដីកាដំណោះស្រាយ គឺមានសុពលភាពនោះ ជនជាប់ចោទត្រូវបានឃុំខ្លួនជាបន្តទៀតស្របតាមវិធាន៨២.១។ យ៉ាងណាមិញ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលរកឃើញផ្សេងពីសុពលភាព ដែលមាននៅផ្នែកនៃការឃុំខ្លួនដែលមាននៅក្នុងសេចក្តីសម្រេចរបស់ អបជ លើដីកាដំណោះស្រាយក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវនូវអំណាចរបស់ខ្លួនស្របតាមវិធាន ៨២.២ ក្នុងការបន្តឃុំខ្លួនជនជាប់ចោទដែរ[១៦]។ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង នៅពេលសវនាការស្តីពីការឃុំខ្លួនរួចហើយ ក.ស.ច.ស និង អ.ប.ជ បានយល់ឃើញយ៉ាងស៊ីសង្វាក់គ្នា -អំពីមូលដ្ឋាននៃការពិនិត្យភស្តុតាងដែលមាន- ថាការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នគឺជាការត្រឹមត្រូវ[១៧]។ នាពេលថ្មីៗនេះ ក.ស.ច.ស បានរកឃើញ

---

[១៥] វិធាន ៨២(២) នៃវិធានផ្ទៃក្នុង។

[១៦] សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានហេតុផលដែលនាំឲ្យជឿបានថា ជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ហើយថាការឃុំខ្លួនមានភាពចាំបាច់ដើម្បីធានាអំពីវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ។ *សូមមើល* សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៨ ដល់ ៣៩។ អង្គជំនុំ ជម្រះសាលាដំបូងបានបង្ហាញថា អង្គជំនុំជម្រះបានធ្វើការពិចារណាលើអំណះអំណាងនានារបស់ភាគីស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ក៏ដូចជាមូលដ្ឋាននានាដែលជនជាប់ចោទត្រូវបានឃុំឃាំងនៅក្នុងដីកាដំណោះស្រាយ និងសាលដីការបស់ អបជ ស្តីពីដីកាដំណោះស្រាយ។ *សូមមើល* សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៩។

[១៧] ប្រតិចារឹកអំពីសវនាការស្តីពីការឃុំខ្លួន, ប្រតិចារឹក ៥៤ ដល់ ៥៩។ ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ការិយាល័យសហចៅក្រមស៊ើបអង្កេត, ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧, ឯកសារ C9។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ០១), អង្គបុរេជំនុំជម្រះ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨, ឯកសារ C11/54។

ហើយអង្គបុរេជំនុំជម្រះក៏បានបញ្ជាក់អះអាងថា ការបន្តឃុំខ្លួនជនជាប់ចោទ គឺជាទង្វើដែលធានាថា ជនជាប់ចោទនឹងមានវត្តមាននៅពេលជំនុំជម្រះ, ការពារសន្តិសុខដល់ជនជាប់ចោទ, រក្សាសណ្តាប់ធ្នាប់សាធារណៈ និងបង្ការកុំឱ្យមានហានិភ័យ ដែលជនជាប់ចោទគាបសង្កត់ទៅលើសាក្សី ឬបំផ្លាញភស្តុតាង ប្រសិនបើពួកគេត្រូវបានដោះលែងឱ្យមានសេរីភាព[១៨]។

៩. នៅពេលសវនាការ ជនជាប់ចោទមិនបានលើកឡើងនូវការប្រែប្រួលណាមួយនៅក្នុងកាលៈទេសៈដែលផ្ទុយពីការសន្និដ្ឋានយ៉ាងស៊ីសង្វាក់គ្នារបស់ ក.ស.ចៅ.ស និង អ.ប.ជ ដែលថាការឃុំខ្លួននៅតែត្រូវបានធ្វើឡើងដោយមានសំអាងហេតុគ្រប់គ្រាន់នោះទេ[១៩]។ ស្រដៀងគ្នានេះដែរ គ្មានចំណុចណាមួយនៅក្នុងបណ្តឹងសាទុក្ខដែលជនជាប់ចោទអះអាងថា មានមូលដ្ឋានភស្តុតាងមិនគ្រប់គ្រាន់សម្រាប់ការបញ្ជាក់អះអាងរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការបន្តឃុំខ្លួនជនជាប់ចោទ ដោយអនុលោមតាមវិធាន ៨២ នោះឡើយ។ ដូចនេះ ការអះអាងរបស់ជនជាប់ចោទដែលថា ការបន្តឃុំខ្លួនគាត់គ្មានសុពលភាពនោះ គឺគ្មានហេតុផលឡើយ។

---

ដីកាបង្គាប់ពន្យារថិរវេលាឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ការិយាល័យសហចៅក្រមស៊ើបអង្កេត, ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨, ឯកសារ C9/3។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឱ្យពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៣), អង្គបុរេជំនុំជម្រះ, ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៩, ឯកសារ C9/4/6។ ដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ការិយាល័យសហចៅក្រមស៊ើបអង្កេត, ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៩ ឯកសារ C9/6។ ដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ការិយាល័យសហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០, ឯកសារ D427 ("ដីកាដំណោះស្រាយ") កថាខណ្ឌ ១៦១៤ ដល់ ១៦២៤។

[១៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦២២ ដល់ ១៦២៤។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយៈ មូលហេតុដើម្បីបន្តការឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ និង ១៤៦), អង្គបុរេជំនុំជម្រះ, ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១១, ឯកសារ D427/3/13។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ១៤៥ និង ១៤៦), អង្គបុរេជំនុំជម្រះ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារ D427/2/15។

[១៩] *សូមមើល* ប្រតិចារឹកអំពីសវនាការស្តីពីការឃុំខ្លួន, ទំព័រ ៧៩-៨១ (ការលើកឡើងរបស់ជនជាប់ចោទអំពីមូលដ្ឋានសម្រាប់ការឃុំខ្លួន)។

## V. ជនជាប់ចោទខកខានមិនបានពន្យល់ថាផលប្រយោជន៍របស់ខ្លួនបានទទួលរងផលប៉ះពាល់បែបណាខ្លះ ដោយសារកំហុសដែលខ្លួនបានអះអាងថាមាននៅក្នុងសេចក្ដីសម្រេចឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ

១០. ពាក្យពេចន៍ទាំងមូលនៃវិធាន ១០៤ បង្ហាញថា បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង រួមទាំងសេចក្ដីសម្រេចឃុំខ្លួនស្របតាមវិធាន ៨២ គឺត្រូវតែបង្ហាញអំពី "មូលដ្ឋាននៃការភ័ន្តច្រឡំ ដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង" *និង* "ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ" ដែលកើតឡើងដោយសារការភ័ន្តច្រឡំនោះ[២០]។ ដោយមិនអើពើនឹងបទដ្ឋាននេះ នៅក្នុងបណ្ដឹងសាទុក្ខខកខានមិនបានពន្យល់ - ឬលើកឡើង-ថាសេចក្ដីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង បាននាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ។

១១. ចំពោះការលើកឡើងរបស់ជនជាប់ចោទអំពីប្រភេទនៃព្យសនកម្មណាមួយនោះ វាមានការពាក់ព័ន្ធទៅនឹងភាពអយុត្តិធម៌តាមការសន្មត នៃសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អ.ប.ជ ទាក់ទិននឹងជនជាប់ចោទ[២១]។ ជាពិសេស ជនជាប់ចោទលើកឡើងម្ដងហើយម្ដងទៀតនូវការអះអាងដែលខ្លួនបានធ្វើឡើងនៅពេលសវនាការស្ដីពីការឃុំខ្លួន ពោលគឺថាព្យសនកម្មជាក់ស្ដែងបានកើតឡើងពីព្រោះ "ស្ថាប័នតុលាការមួយនៅ អ.វ.ត.ក ដែលមានភារកិច្ចជំនុំជម្រះដោយត្រឹមត្រូវ និងយុត្តិធម៌ បានជាប់ពាក់ព័ន្ធនឹងទង្វើដែលគេចាត់ទុកថាជាអំពើអយុត្តិធម៌"[២២]។ ទោះបីជាយ៉ាងណាក៏ដោយ បទដ្ឋានសម្រាប់បណ្ដឹងសាទុក្ខភ្លាមៗទៅអង្គជំនុំជម្រះតុលាការកំពូលតម្រូវឲ្យមានការបង្ហាញអំពីព្យសនកម្មដែលកើតចេញពីការភ័ន្តច្រឡំរបស់ *អង្គជំនុំជម្រះសាលាដំបូង* មិនមែនអង្គបុរេជំនុំជម្រះនោះទេ[២៣]។

---

[២០] *សូមមើល* វិធាន ១០៤(១) (កថាខណ្ឌទីពីរ)។

[២១] *សូមមើល* បណ្ដឹងសាទុក្ខរបស់មេធាវី, កថាខណ្ឌ ២២ ដល់ ២៩ និង ៣២។

[២២] បណ្ដឹងសាទុក្ខរបស់មេធាវី កថាខណ្ឌ ៣២។ ប្រតិចារឹកអំពីសវនាការស្ដីពីការឃុំខ្លួន ទំព័រ ១៧ [ដោយបានលើកឡើងថា "ការប៉ះពាល់សិទ្ធិនឹងកើតមានឡើង នៅពេលអង្គជំនុំជម្រះមិនគោរពតាមច្បាប់របស់ខ្លួន"។

[២៣] *សូមមើល* វិធាន ១០៤(១) (ដែលលើកឡើងថា បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំដែលស្ដែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់*អង្គជំនុំជម្រះសាលាដំបូង*ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងសាទុក្ខ") (ការបញ្ជាក់បន្ថែម)។

១២. លើសពីនេះទៀត លក្ខខណ្ឌកំណត់"មូលដ្ឋាននៃការភ័ន្តច្រឡំ" និង "ការប៉ះពាល់" សម្រាប់បណ្តឹងសាទុក្ខភ្លាមៗនៅ អ.វ.ត.ក បង្ហាញថា អង្គហេតុដែលគ្រាន់តែថា ជនជាប់ចោទមិនឯកភាពជាមួយនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង មិនមែនជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់បណ្តឹងសាទុក្ខនោះទេ។ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលចែងពីការពិនិត្យមើលបណ្តឹងសាទុក្ខភ្លាមៗ មិនត្រូវបានរៀបចំឡើង ដើម្បីអនុញ្ញាតឱ្យម្ចាស់បណ្តឹងសាទុក្ខគ្រាន់តែធ្វើការប្តឹងឡើងវិញលើបញ្ហាដដែលៗដែលខ្លួនបានប្តឹងនៅចំពោះមុខតុលាការជាន់ទាបហើយនោះទេ។ ផ្ទុយទៅវិញ វិធានផ្ទៃក្នុងកំណត់យន្តការសម្រាប់ពិនិត្យមើលឡើងវិញចំពោះតែបញ្ហាដែលពាក់ព័ន្ធនឹងកំហុសនិងការប៉ះពាល់ប្រយោជន៍ធ្ងន់ធ្ងរតែប៉ុណ្ណោះ។ ការកំណត់យន្តការសម្រាប់ពិនិត្យបណ្តឹងសាទុក្ខនេះបែបនេះ គឺជាការត្រឹមត្រូវនៅក្នុងបរិបទពិសេសនេះ និងមានលក្ខណៈស្របគ្នានឹងវិធីសាស្ត្ររបស់តុលាការអន្តរជាតិដទៃទៀត[២៤]។

១៣. ចំពោះការអះអាងរបស់ជនជាប់ចោទថា កាភ័ន្តច្រឡំអង្គច្បាប់ដែលខ្លួនគិតថាមាននៅក្នុងសេចក្តីសម្រេចស្តីពីការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញពីព្យសនកម្ម - ការអះអាងបែបនេះផ្ទុយគ្នានឹងពាក្យពេចន៍ទាំងមូលនៃវិធាន ១០៤(១) ដែលកំណត់ពីបទដ្ឋានពីរចំណុច សម្រាប់បណ្តឹងសាទុក្ខដែលតម្រូវឱ្យមានការបង្ហាញឱ្យបានច្បាស់លាស់នូវការភ័ន្តច្រឡំ ក៏ដូចជា បង្ហាញពីការប៉ះពាល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខដែលបណ្តាលមកពីការភ័ន្តច្រឡំនោះ[២៥]។ ការបកស្រាយវិធាន ១០៤(១) ដើម្បីគ្រាន់តែអនុញ្ញាតឱ្យមានបណ្តឹងសាទុក្ខភ្លាមៗ ដោយសារតែមានការភ័ន្តច្រឡំ ប៉ុន្តែគ្មានការលើកឡើងពីការប៉ះពាល់សិទ្ធិ នឹងធ្វើឱ្យចំណុចទីពីរនៃបទដ្ឋានប្តឹងសាទុក្ខដែលបានចែង

---

[២៤] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Rutaganda* អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ ICTR ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៣ កថាខណ្ឌ ១៥ (ដែលលើកឡើងថា "ផ្ទុយទៅនឹងនីតិវិធីនៅក្នុងប្រព័ន្ធច្បាប់ជាតិមួយចំនួន [នីតិវិធីបណ្តឹងឧទ្ធរណ៍របស់តុលាការ ICTY និង ICTR] មានលក្ខណៈកែឱ្យត្រឹមត្រូវ ដូចនេះហើយ "មិនមែនជាឱកាសសម្រាប់ភាគីនានាធ្វើការតវ៉ា ឡើងវិញអំពីរឿងក្តីរបស់ខ្លួននោះទេ")។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Muvunyi* អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ ICTR ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១១ (ដែលលើកឡើងថា "ភាគីមួយមិនអាចលើកឡើងម្តងហើយម្តងទៀតពីទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍ដែលមិនបានទទួលជោគជ័យនៅពេលសវនាការនោះទេ លើកលែងតែភាគីនោះអាចបង្ហាញថា ការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងអំពីទឡ្ហីករណ៍ទាំងអស់នោះបានបង្កើតនូវការភ័ន្តច្រឡំដែលធានាឱ្យមានអន្តរាគមន៍ពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍")។

[២៥] *សូមមើល* វិធាន ១០៤(១)។

នៅក្នុងវិធាន ១០៤(១) លែងមានខ្លឹមសារទៀតហើយ។ ការបកស្រាយបែបនេះមានលក្ខណៈ មិនស៊ីសង្វាក់គ្នានឹងវិធានដំបូងនៃ ការបកស្រាយដែលថា "ការបកស្រាយមិនត្រូវធ្វើលើបទប្បញ្ញត្តិ ឬផ្នែកមួយនៃបទបញ្ញត្តិណាមួយហាក់បីដូចជាបទប្បញ្ញត្តិនោះគ្មានន័យនោះទេ។ ការសន្មតទុកជាមុនត្រូវបានធានាថា អ្នកបង្កើតច្បាប់ប្រាកដជាបានអនុម័ត ឬឯកភាពតាមវិធាននានា ដែលត្រូវបានពិចារណាច្បាស់លាស់ និងមានអត្ថន័យគ្រប់គ្រាន់ នៅគ្រប់ធាតុផ្សំទាំងអស់នៃវិធានទាំងនោះ"[២៦]។

១៤. មានការបង្ហាញយ៉ាងច្បាស់ថា ជនជាប់ចោទមិនបានទទួលរងនូវព្យសនកម្ម ឬការប៉ះពាល់ជាក់ស្តែងណាមួយដែលកើតចេញមកពីសេចក្តីសម្រេច ស្តីពីការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមគោលការណ៍ដែលត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់ ក្នុងការវាយតម្លៃថា តើការដោះលែងជាបន្ទាន់ គឺជាដំណោះស្រាយដែលមានសមាមាត្រដែរ ឬទេនៅក្នុងដំណាក់កាលនេះ[២៧]។ លើសពីនេះទៀត ដោយមិនគិតពីវិការៈណាមួយនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អ.ប.ជ និង/ឬ ផ្នែកស្តីពីការឃុំខ្លួនរបស់សាលដីកានោះ អង្គជំនុំជម្រះសាលាដំបូងមានអំណាចឯករាជ្យក្នុងការបង្គាប់ឱ្យមានការឃុំខ្លួនស្របតាមវិធាន ៨២ ហើយអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញយ៉ាងច្បាស់លាស់ អំពីមូលដ្ឋានដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចបន្តឃុំខ្លួនជនជាប់ចោទ[២៨]។ ជាចុងក្រោយ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការដោះលែងជាបន្ទាន់ គឺជាដំណោះស្រាយត្រឹមត្រូវសម្រាប់កំហុសនីតិវិធីនៅក្នុងសាលដីការបស់ អ.ប.ជ ស្តីពីដីកាដំណោះស្រាយក៏ដោយ ក៏លទ្ធផលជាក់ស្តែងនឹងមិនមានភាពខុសប្លែកគ្នានោះទេ ពីព្រោះដោយសារ អង្គជំនុំជម្រះសាលាដំបូង មុខជានឹងមានអំណាចក្នុងការបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាថ្មីឡើងវិញបាន អនុលោមតាមវិធាន៨២ នៃវិធានផ្ទៃក្នុង[២៩]។

---

[២៦] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadić*, Judgement, IT-94-1-A អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២៨៤។

[២៧] *សូមមើល* ដូចខាងលើ ផ្នែក III។

[២៨] *សូមមើល* សេចក្តីសម្រេចលើការឃុំខ្លួនរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣៨ ដល់៣៩។

[២៩] ដូចបានកត់សំគាល់ខាងលើ នៅក្នុងវិធានផ្ទៃក្នុងមិនមានអ្វីដែលគាំទ្រចំពោះសញ្ញាណដែលថា វិការៈនៃនីតិវិធីមួយនៅក្នុងការសំរេចឱ្យឃុំខ្លួននៅក្នុងផ្នែកណាមួយនៃដំណើរការនីតិវិធីដើរតួជាការរារាំងមួយជាអចិន្ត្រៃយ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ននាពេលអនាគតនោះទេ។ ម្យ៉ាង

១៥. លើសពីនេះទៅទៀត នៅពេលដែលជនជាប់ចោទលើកសំអាងលើការអះអាងមួយ "អំពី *គោលការណ៍ស្ដីពីដំណោះស្រាយស្ពាពរ* (*Ultimum remedium*) ដែលធ្លាប់បានទទួលស្គាល់ជាអន្តរជាតិ " ដើម្បីគាំទ្រចំពោះការបន្តតវ៉ាទាមទាររបស់គាត់ដែលថា វិធីសាស្ត្ររបស់អង្គបុរេជំនុំជម្រះមិនត្រឹមត្រូវ[៣០] បញ្ហានៅក្នុងបណ្ដឹងសាទុក្ខនៅទីនេះ គឺមិនមែនជាបញ្ហាអំពីថា តើអង្គបុរេជំនុំជម្រះគួរបានធ្វើសកម្មភាពផ្សេងពីនេះវិញ ឬមួយយ៉ាងណានោះទេ[៣១] ។ ផ្ទុយទៅវិញ សំនួរដែលពាក់ព័ន្ធនោះគឺថា តើអង្គជំនុំជម្រះសាលាដំបូង-ក្នុងការវាយតម្លៃរបស់ខ្លួនអំពីដំណោះស្រាយផ្សេងៗ- តើមានការភ័ន្តច្រឡំនៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងលក្ខណៈមួយដែលធ្វើឲ្យមានការខូចខាតដល់សិទ្ធិ ឬផលប្រយោជន៍របស់ជនជាប់ចោទដែរឬទេ?

---

ទៀត គ្មានមូលហេតុណាដើម្បីធ្វើឲ្យជឿថា ឯករាជ្យភាពរបស់អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន៨២ ស្ដីពីសិទ្ធិអំណាចក្នុងការបង្គាប់ឲ្យឃុំខ្លួន "នៅពេលណាមួយក្នុងអំឡុងពេលនៃដំណើរការនីតិវិធី" ត្រូវបានរងផលប៉ះពាល់ដោយសារការរកឃើញថា អង្គបុរេជំនុំជម្រះបានប្រព្រឹត្តកំហុសឆ្គងណាមួយផ្នែកនីតិវិធីឡើយ។

[៣០] *សូមអាន* បណ្ដឹងសាទុក្ខរបស់មេធាវីជនជនចាប់ចោទ, កថាខណ្ឌទី២២-២៨ ។ សហព្រះរាជអាជ្ញា សូមកត់សំគាល់ថា ការសំដែងឲ្យឃើញជាពិសេសណាមួយអំពីគោលការណ៍នេះដែលមានការគាំទ្រយ៉ាងស្វិតស្វាញ ហើយដែលគួរឲ្យសង្ស័យយ៉ាងខ្លាំង។ *សូមអាន* បណ្ដឹងសាទុក្ខរបស់មេធាវី, កថាខណ្ឌទី២២។ មាត្រា៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលចែងអំពីសញ្ញាណដែលមានការកំហិតខ្លាំងជាងនេះ គឺបានន័យថា វាមិនមែនជាវិធានទូទៅនោះទេ ដែលថាការឃុំខ្លួនបុគ្គលដើម្បីរង់ចាំសវនាការជំនុំជម្រះក្ដី។ នៅអវតក នេះមិនមែនជា "វិធានទូទៅ" នោះឡើយដែលថា បុគ្គលត្រូវតែបានធ្វើការឃុំខ្លួនដើម្បីរង់ចាំសវនាការជំនុំជម្រះក្ដី។ សូមអាន វិធាន៦៣-៦៤ ,៨២។ ក៏ប៉ុន្តែ នៅពេលដែលជនជាប់ចោទណាម្នាក់ត្រូវបានឃុំខ្លួនហើយ គឺមានការសន្មត់មួយថាការឃុំខ្លួននឹងត្រូវបន្តនៅក្នុងទូទាំងអំឡុងពេលនៃសវនាការជំនុំជម្រះក្ដី។ សូមអាន វិធាន៦៤ (ការអនុញ្ញាតឲ្យដោះលែងជនជាប់ចោទណាម្នាក់ពីការឃុំខ្លួនបណ្ដោះអាសន្ន នៅក្រោយពេលមានការបង្ហាញអំពីថា "មានការប្រែប្រួលស្ថានភាពណាមួយ")។ វិធាន៨២ នៃវិធានផ្ទៃក្នុងចែងថា "ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះ ជនជាប់ចោទត្រូវស្ថិតនៅក្នុងការឃុំខ្លួនដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបានសំរេចសេចក្ដី")។ នេះគឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តន៍ជាអន្តរជាតិ។ *សូមអាន,* សៀវភៅរបស់លោក Geert-Jean Knoops, ដែលមានចំណងជើង **ទ្រឹស្ដីនិងការអនុវត្តន៍នៃដំណើរការនីតិវិធីរឿងក្ដីព្រហ្មទណ្ឌនៅក្នុងតុលាការអន្តរជាតិ និងតុលាការដែលធ្វើឲ្យទៅជាលក្ខណៈអន្តរជាតិ** (ឆ្នាំ២០០៥), ទំព័រ១៥០ (ដែលទទួលស្គាល់ថា នៅក្រោមប្រពន្ធ័នៃតុលាការ ICTY, ICTR, និង SCSL កាតព្វកិច្ចទទួលខុសត្រូវគឺស្ថិតនៅលើជនជាប់ចោទដែលជាអ្នកត្រូវស្រាយបញ្ជាក់អំពីអង្គហេតុដែលថាជនជាប់ចោទត្រូវតែចូលបង្ហាញខ្លួនដើម្បីទទួលការជំនុំជម្រះក្ដីហើយ មិនត្រូវជ្រៀតជ្រែកនៅក្នុងសវនាការការជំនុំជម្រះក្ដីឡើយ")។

[៣១] តាមពិត ដោយទទួលស្គាល់អំពីអត្ថិភាពនៃកំហុសនីតិវិធីនីតិវិធីនៅក្នុងដីកាសម្រេចលើកដំបូងរបស់ អង្គបុរេជំនុំជម្រះ លើដីកាណោះស្រាយ អង្គជំនុំជម្រះសាលាដំបូង ជាក់ស្ដែងបានយល់ព្រមតាមទឡ្ហីករណ៍របស់ អង្គបុរេជំនុំជម្រះ ថាគួរបានធ្វើសកម្មភាពផ្សេងពីនេះ។ *សូមអាន* ដីកាសម្រេចស្ដីពីការឃុំខ្លួនបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌទី២៩។

## ៦. សេចក្ដីសន្និដ្ឋាន

១៦. សេចក្ដីដូចបានលើកឡើងខាងលើ សហព្រះរាជអាជ្ញា សូមស្នើអង្គជំនុំជម្រះតុលាការកំពូល៖

១) បដិសេធចោលនូវសំណើរបស់ជនជាប់ចោទដែលស្នើសុំទុកជាមោឃៈ ឬកែប្រែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

២) បដិសេធចោលនូវសំណើរបស់ជនជាប់ចោទដែលសុំឱ្យដោះលែងជាបន្ទាន់។

៣) បដិសេធចោលនូវសំណើរបស់ជនជាប់ចោទដែលសុំឱ្យបើកសវនាការលើបញ្ហានេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា** សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |